**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការ សម្រាប់សិក្សា និងរៀបចំសាងសង់ស្តូបអនុស្សាវរីយ៍ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា តាមរយៈនយោបាយឈ្នះ ឈ្នះ របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការ សម្រាប់សិក្សា និងរៀបចំសាងសង់ស្តូបអនុស្សាវរីយ៍ នៃការបញ្ចប់សង្គ្រាម ស៊ីវិលនៅកម្ពុជា តាមរយៈនយោបាយ ឈ្នះ ឈ្នះ រួមមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | ប្រធាន |
| ២. រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ០១រូប | អនុប្រធាន |
| ៣. រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប | អនុប្រធាន |
| ៤. រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប | អនុប្រធាន |
| ៥. រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ០១រូប | សមាជិក |
| ៦. រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ០១រូប | សមាជិក |
| ៧. អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៨. អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៩. អគ្គនាយក គយ និងរដ្ឋាករកម្ពុជា | សមាជិក |



www.pheakdeylaw.com

១០. អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ — សមាជិក
១១. ទីប្រឹក្សា-នាយកខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ និងជាអគ្គនាយកនយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ — សមាជិកប្រចាំការ
១២. អគ្គលេខាធិការ ក្រសួងការពារជាតិ — សមាជិក
១៣. អគ្គនាយក ភស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ — សមាជិក
១៤. អគ្គនាយក យោធសេវា ក្រសួងការពារជាតិ — សមាជិក
១៥. អគ្គនាយក មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម — សមាជិក
១៦. នាយករង ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី ០១រូប — សមាជិក
១៧. មេបញ្ជាការរង កងទ័ពជើងគោក និងជាមេបញ្ជាការបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម — សមាជិក
១៨. នាយករង នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ០១រូប — សមាជិក ។

**ប្រការ២.-**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចទទួលខុសត្រូវ ៖

- រៀបចំប្លង់ទីតាំងរួម ប្លង់ស្ថាបត្យកម្ម ប្លង់បេនាសម្ព័ន្ធ ប្លង់សាងសង់ ប្លង់បំពាក់គ្រឿងសម្ភារៈតុបតែង និងថវិកាចំណាយលើការសាងសង់ ជូននាយករដ្ឋមន្ត្រី ពិនិត្យ និងសម្រេច
- រៀបចំផែនការសាងសង់ និងតាមដានត្រួតពិនិត្យការអនុវត្ត ព្រមទាំងសម្របសម្រួលការងារជាមួយ គ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងគម្រោង និងរាយការណ៍ជូន និងសុំសេចក្តីសម្រេចពីនាយករដ្ឋមន្ត្រី ដើម្បីឲ្យការសាងសង់នេះសម្រេចបានទាន់ពេលវេលា នៃកិច្ចសន្យាសាងសង់
- អនុវត្តភារកិច្ចដទៃទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ៣.-**

គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារមួយ ជាសេនាធិការក្នុងការសម្របសម្រួលការងារប្រចាំថ្ងៃ ដឹកនាំដោយ ឯកឧត្តម ណឹម សុវត្ថិ ជាប្រធាន និងឯកឧត្តម ហ៊ុន ម៉ាណែត ជាអនុប្រធានប្រចាំការ ។ សមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មការ ។

**ប្រការ៤.-**

អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។ គណៈកម្មការនេះអាចប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសម្របសម្រួលការងារ ។

**ប្រការ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកគណៈកម្មការដូចមានចែងក្នុងប្រការ ១ និងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ១០ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com